# ពរជ័យនៃដំណឹងល្អមានសំរាប់មនុស្សទាំងអស់

អែលឌើរ យ៉ូសែប ដបុលយូ ស៊ីតាទី
នៃពួកចិតសិបនាក់

*កូនចៅរបស់ព្រះនៅលើផែនដីសព្វថ្ងៃនេះ មានឱកាសដើម្បីយល់អំពីផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់សំរាប់ខ្លួន កាន់តែបានច្បាស់លាស់ ជាងពេលណាៗទាំងអស់ ។*

ពីរបីសប្តាហ៍កន្លងទៅ អែលឌើរ មីលរីន អ ផាគីនស៍ ដែលកំពុងបំរើជាពួកចិតសិបនាក់ប្រចាំតំបន់ មករដ្ឋអាឡាស្កា និងខ្ញុំ បានឈរនៅលើវេទិកាខាងមុខក្រុម ជំនុំនៅស្តេក វ៉ានខៅវើរ កូឡុំបៀរអង់គ្លេស នៅប្រទេសកាណាដា ។ គាត់បានអញ្ជើញឱ្យពួកបរិសុទ្ធពិចារណាអំពីរូបភាព ដែលនៅខាង មុខពួកគេ ដោយសម្លេងរំជួលចិត្ត ។ ដោយជាកូនចៅនៃពួកអ្នកត្រួសត្រាយផ្លូវរទេះរុញ និងជាអ្នកត្រួសត្រាយផ្លូវដែលផ្លាស់ប្រែចិត្តម្នាក់ នៃសាសនាចក្រមកពីជាតិសាសន៍អាហ្វ្រិកយ៉ាងឆ្ងាយ កំពុងបំរើព្រះអម្ចាស់ជាមួយគ្នា ។ ចាប់តាំងពីការចាប់ផ្តើមដោយកំសត់ នៅភូមិហ្វាយែត ក្រុងនូយ៉ោក 180 ឆ្នាំកន្លងទៅ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ បានប្រែក្លាយជាជំនឿជាសាកលមួយ ។ ខ្ញុំឈរនៅទីនេះ ធ្វើជាសាក្សីម្នាក់ នៃកិច្ចការដ៏អស្ចារ្យនេះ ។ ខ្ញុំអធិស្ឋានសូមឱ្យ ព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងគង់នៅជាមួយអ្នករាល់គ្នា ហើយនៅជាមួយខ្ញុំ នៅពេលខ្ញុំចែកចាយគំនិតមួយចំនួននាពេលរសៀលនេះ ។

ខ្ញុំមានអំណរគុណចំពោះកូនសោនៃវិវរណៈ នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយនេះ ។ តាមរយៈការអនុវត្តនឹកូនសោ ទាំងនោះ តាមរយៈពួកព្យាការីដែលនៅរស់ ចាប់តាំងពីការស្តារឡើងវិញ នោះកូនចៅរបស់ព្រះនៅលើផែនដីសព្វថ្ងៃនេះ មានឱកាសដើម្បីយល់អំពីផែនការនៃសុភមង្គលរបស់ទ្រង់សំរាប់ពួកគេ កាន់តែបានពេញលេញជាងពេលណាៗទាំងអស់ ។

សេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌យើង បានបង្ហាញជាភស្តុតាង នៅពេលផ្លូវត្រូវបានបើកសំរាប់ទាំងជនដែលរស់នៅ និងមរណជនគ្រប់ជាតិសាសន៍ នាពេលឥឡូវនេះ និងក្នុងពេលអនាគត ដើម្បីទទួលការលើកដំកើងនៅក្នុងវត្តមានរបស់ទ្រង់ ស្របតាមការអនុវត្តន៍សិទ្ធិសេរីភាពរបស់ពួកគេ ។ បទដ្ឋានគឺមានដូចគ្នា ហើយពរជ័យគឺមានដូចគ្នាចំពោះ មនុស្សទាំងអស់ ។ ព្រះបានបញ្ជាក់សារជាថ្មីថា ទ្រង់មិនរើសមុខជនណាឡើយ ។

ដំណឹងល្អបានចេញទៅទូទាំងផែនដី តាមលំនាំមួយដែលអះអាងថា ព្រះរាជបំណងទាំងឡាយរបស់ព្រះក្នុងការនាំមកនូវអមតភាព និងជីវិតដ៏អស់កល្បជានិច្ចដល់មនុស្ស ត្រូវបានបំពេញ ។

បន្ទាប់ពីការធ្លាក់ ឪពុកម្តាយដំបូងរបស់យើងគឺ អ័ដាម និងអេវ៉ា បានចុះសេចក្តីសញ្ញាដ៏អស់កល្បជានិច្ចមួយជាមួយព្រះសំរាប់សេចក្តីសង្គ្រោះរបស់ពួកគាត់ ។ 1 នៅពេលកូនចៅរបស់អ័ដាមចំរើនឡើង នោះបានបែកចេញជាពីរក្រុម ។

ក្រុមមួយ ត្រូវបានដឹកនាំដោយអេណុក ដែលបានរក្សាសេចក្តីសញ្ញា 2 បានយ៉ាងល្អ ដែលពួកគេមិនអាចទុកឱ្យនៅលើផែនដីតទៅទៀត ។ ដូច្នេះព្រះអម្ចាស់បានប្រមូលពួកគេឱ្យទៅជាមួយទ្រង់ ។

ក្រុមទីពីរ បានគ្របដណ្ដប់ដោយសេចក្ដីទុច្ចរិតយ៉ាងខ្លាំង ដែលពួកគេបានរងទុក្ខពីការជំនុំជំរះរបស់ព្រះ។ ទឹកជំនន់បានលេបត្របាក់ពួកគេ បន្សល់ទុកតែគ្រួសាររបស់ណូអេ ជាកូនចៅ 3 សុចរិតរបស់អេណុស។4

ព្រះដាក់ណូអេក្រោមសេចក្ដីសញ្ញាដោយបានសន្យាបន្ថែមថា ជីវិតនៅលើផែនដីនឹងមិនត្រូវបានបំផ្លាញ ដោយទឹកជំនន់ទៀតឡើយ។5

នៅពេលគ្រួសាររបស់ណូអេចំរើនឡើងម្ដងទៀត មានកូនចៅជាច្រើនបានប្រែជាទុច្ចរិត។ ដោយសារពួកគេដឹកនាំ ដោយភាពឆ្មើងឆ្មៃ នោះពួកគេបានសង់ប៉មបាបិល។ ព្រះបណ្ដោយឱ្យសេចក្ដីជំនុំជំរះពីស្ថានសួគ៌ធ្លាក់មកលើពួកគេ។ ភាសារបស់ពួកគេត្រូវបានបំភាន់ ហើយពួកគេបានបែកខ្ចាយទៅកន្លែងផ្សេងៗ។ មានតែមនុស្សមួយចំនួនដែលគោរពប្រតិបត្តិប៉ុណ្ណោះ នៅមានជីវិតរស់។6

នៅក្នុងចំណោមអ្នកដែលបានរួចជីវិត គឺមានបងប្រុសរបស់យ៉ារេឌ ជាបុរសដែលមានជំនឿដ៏មហិមា បានសុំអង្វរព្រះអម្ចាស់ជំនួសពួកសាសន៍យ៉ារេឌសុចរិត។ ព្រះអម្ចាស់បាននាំពួកគេទៅកាន់ទ្វីបអាមេរិក ដោយសន្យាថា បើសិនជាពួកគេបំរើទ្រង់ នោះពួកគេនឹង "បានរួចពីសេវកភាព និងពីការជាប់ឃុំឃាំង និងពីសាសន៍ឯទៀតទាំងអស់នៅក្រោមមេឃ"។7 ក្រោយមក ពួកសាសន៍នីហ្វៃក៏ត្រូវបាននាំឱ្យទៅកាន់ទ្វីបដដែលនេះផងដែរ។ នៅទីបញ្ចប់ អារយ្យធម៌របស់ពួកសាសន៍យ៉ារេឌ និងពួកសាសន៍ នីហ្វៃ ត្រូវបានបំផ្លិចបំផ្លាញ ដោយសារពួកគេមិនបានបង្ហាញពីភាពស្មោះត្រង់។

បុរសដែលមានសេចក្ដីជំនឿមហិមាម្នាក់ទៀត ត្រូវបានរក្សាទុក គឺជាអាប្រាហាំ ជាពូជអំបូររបស់ណូអេ ដែលបានដឹកនាំទៅស្រុកកាណាន។ ព្រះបានដាក់អាប្រាហាំក្រោមសេចក្ដីសញ្ញា ដោយបានសន្យាបន្ថែមថា ពូជពង្ស របស់គាត់ នឹងរីកចំរើនដូចជាផ្កាយ នៅលើមេឃ 8 ហើយថាពូជរបស់លោក "...អស់ទាំងគ្រួសារនៅលើផែនដីនឹងបានពរ"។9 ប្រជាជននៅក្នុងការសន្យាទាំងអស់នោះគឺជាពូជអំបូររបស់ណូអេ ដែលបានខ្ចាត់ព្រាត់មកពី ប៉មបាបិល ដែលជាទូទៅត្រូវបាន ស្គាល់ថាជាពួកសាសន៍ដទៃ។

ព្រះបានរំលឹកសេចក្ដីសញ្ញាជាមួយកូនប្រុសរបស់អ័ប្រាហាំ គឺ អ៊ីសាក ហើយនឹងចៅ យ៉ាកុប ដែលក្លាយជាអ៊ីស្រាអែល។

ដោយសារតែកូនចៅរបស់អ៊ីស្រាអែល មិនអាចប្រកាន់ខ្ជាប់នឹងលក្ខខណ្ឌនៃសេចក្ដីសញ្ញា នោះត្រូវបានផ្លាស់ប្ដូរនៅអំឡុងពេលគ្រាកាន់កាប់ត្រួតត្រារបស់ម៉ូសេ។ សេចក្ដីសញ្ញាទាបជាងមួយ គឺត្រូវបានណែនាំ និងបន្តនៅក្នុងចំណោមកូនចៅរបស់អ៊ីស្រាអែលរហូតដល់ព្រះគ្រីស្ទបានស្ដារឡើងវិញនូវដំណឹងល្អពេញលេញ អំឡុងពេលការបំរើរបស់ទ្រង់ក្នុងជីវិតរមែងស្លាប់។10

បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ ព្រះអង្គសង្គ្រោះបានឱ្យសញ្ញាថា ពេលវេលាសំរាប់ដំណឹងល្អដល់ពួកសាសន៍ដទៃបានមកដល់ហើយ។ 11 នៅក្នុងរឿងប្រៀបប្រដូចពីមុន អំពីអ្នកធ្វើការនៅក្នុងចំការទំពាំងបាយជូរ ទ្រង់បានបើកសម្ដែងថា ពួកសាសន៍ដទៃនឹងត្រូវបានជួប ហើយអញ្ជើញម្ដងម្នាក់ៗ។ ទោះជាយ៉ាងណាក៏ដោយ ពរជ័យទាំងឡាយនឹងត្រូវបានផ្ដល់ដូចគ្នា ដោយមិនគិតសំខាន់អំពីលំដាប់លំដោយនៃការអញ្ជើញនោះទេ។12

បន្ទាប់ពីការយាងឡើងទៅវិញរបស់ព្រះអង្គសង្គ្រោះ សាវកជាអធិតបី ពេត្រុស ដែលជាកូនចៅរបស់អ៊ីស្រាអែល បានកាន់កូនសោទាំងឡាយនៃបព្វជិតភាព ដើម្បីគាត់ដឹកនាំសាសនាចក្រ ។ វាគឺជារឿងសំខាន់ ដែលសូម្បីតែព្រះអង្គសង្គ្រោះបានផ្ដល់ការអនុញ្ញាតរួចទៅហើយ ពេត្រុសបានធ្វើបុណ្យជ្រមុជទឹកឱ្យពួកសាសន៍ដទៃ ដំបូងគេ ឈ្មោះ កូនេលាស ជាមនុស្សតែម្នាក់គត់ ដែលបានទទួលវិវរណៈជាក់លាក់ដើម្បីធ្វើដូច្នោះ ។ 13

ការបំរើចំពោះពួកសាសន៍ដទៃ ត្រូវបានរំខានដោយការធ្វើឃាតពេត្រុស 14 ហើយសេចក្ដីស្លាប់របស់សាវកដទៃទៀតដែលធ្វើឱ្យកូនសោទាំងឡាយនៃបព្វជិតភាព ត្រូវបានដកយកចេញពីផែនដី ។ រយៈពេលការក្បត់សាសនាដ៏យូរអង្វែងបានកើតឡើង ។

កូនសោទាំងឡាយត្រូវបានស្ដារឡើងវិញដោយពេត្រុស យ៉ាកុប យ៉ូហាន ដែលបានរស់ឡើងវិញ នៅឆ្នាំ 1829 មកឱ្យយ៉ូសែប ស្ម៊ីធ ពីមុនសាសនាចក្រត្រូវបានរៀបចំឡើងបន្តិច ។ ដំណឹងល្អដ៏ពេញលេញត្រូវបានមានសារ ជាថ្មីនៅលើផែនដី ហើយបានចាប់ផ្ដើមផ្សព្វផ្សាយទៅក្នុងចំណោមជាតិសាសន៍នៃពួកសាសន៍ដទៃ ជាសេចក្ដីសញ្ញាថ្មី និងអស់កល្បជានិច្ច ។

តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់បានបើកសម្ដែងថាការកំណត់បទដ្ឋានតាមរបៀប ដែលជាតិសាសន៍ដទៃ ត្រូវបានអញ្ជើញ រួមមានសមត្ថភាពដើម្បីចិញ្ចឹមបីបាច់នគរព្រះខាងវិញ្ញាណ និងខាងរាងកាយ នៅពេលដែលវាត្រូវបាន ស្ថាបនានៅលើផែនដីសំរាប់ជំនាន់ចុងក្រោយ ។ 15

យើងមើលឃើញថា នៅពេលសាសនាចក្រដែលបានស្ដារឡើងវិញ បានចាប់ផ្ដើមស្ថាបនានៅលើផែនដី ពួកព្យាការីដែលនៅរស់បានស្វែងរក និងធ្វើតាមឆន្ទៈរបស់ព្រះអំពីរបៀបដែលដំណឹងល្អ គួរតែចេញទៅផ្សព្វផ្សាយក្នុងចំណោម ជាតិសាសន៍នានា ។

ខ្ញុំបានរស់នៅមើលឃើញពេលវេលាដែលបានទាយទុកដោយព្យាការី ស៊ីណូស នៅក្នុងរូបាធិដ្ឋាននៃដើមអូលីវ នៅពេលពួកសុចរិតមកពីគ្រប់ជាតិសាសន៍លើផែនដី នឹងប្រែក្លាយជាអ្នកទទួលទានសេចក្ដីសញ្ញារបស់ព្រះ ជាមួយអ៊ីស្រាអែល ។ 16

ខ្ញុំបានមើលឃើញផលផ្លែល្អនៃដំណឹងល្អរីកស្គុះស្គាយនៅក្នុងផ្ទះរបស់ខ្ញុំ នៅទ្វីបអាហ្វ្រិក ។ គ្រាន់តែរយៈពេល 30 ឆ្នាំ ប៉ុណ្ណោះមានពួកបរិសុទ្ធដល់ទៅ 300,000 នាក់ ។ នៅក្នុងគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អដែលបានស្ដារ ឡើងវិញមានមនុស្សជាច្រើនកំពុងតែស្វែងរកមូលដ្ឋានពិតសំរាប់សេចក្ដីជំនឿរបស់ពួកគេ ។ ក្រុមគ្រួសារជាច្រើនផ្លាស់ពីសហគមន៍ដ៏ដាច់ស្រយាលដើម្បីស្វែងរកអនាគតភ្លឺស្វាង តាមទីក្រុងផ្សេងៗ បានរកឃើញផ្លូវថ្មីដើម្បី កាន់ទំនៀមទំលាប់ គ្រួសាររឹងមាំ ដែលស្ថិតក្រោមការវាយប្រហារកាន់តែខ្លាំងឡើង នៅក្នុងយុគសម័យនៃសាកលភាវូបនីយកម្មនេះ ។ ព្រះវិញ្ញាណរបស់ព្រះអម្ចាស់ កំពុងតែផ្លាស់ប្ដូរប្រកបដោយអានុភាព នៅក្នុងចំណោមមនុស្សទាំងឡាយ ។

វប្បធម៌សេឡេស្ទាលថ្មីកំពុងតែបង្កើតនៅក្នុងគេហដ្ឋានទាំងឡាយ បានចិញ្ចឹមបីបាច់ដោយឆន្ទៈគោរពប្រតិបត្តិតាមដំបូន្មានរបស់ព្យាការីនៅរស់ ឱ្យមានការអធិស្ឋាន និងការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ហើយត្រូវជួបគ្នាមួយសប្ដាហ៍ម្ដង ធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ជាលទ្ធផល មនុស្សជាច្រើនអាចបានដោះឱ្យរួចពីខ្នោះនៃទំនៀមទំលាប់ ដែលរារាំងដល់ការអនុវត្តន៍ សិទ្ធិសេរីភាពរបស់ពួកគេ ។

ជាការបង្ហាញមកពីបទពិសោធន៍ផ្ទាល់ខ្លួន កូនយើងបីនាក់ ថ្មីៗនេះបានរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ ដោយគ្មានបន្ទុកនៃថ្លៃបណ្ណាការ ជាការអនុវត្តន៍តាមទំនៀមទំលាប់ ដែលបានដឹកនាំយុវជនយុវនារីឱ្យរស់នៅជាមួយគ្នា ដោយគ្មានការប្ដេជ្ញាចិត្តត្រឹមត្រូវចំពោះគ្នា ទៅវិញទៅមកឡើយ ។ ឱកាសសំរាប់អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធមួយ នៅក្នុងចំណោមព្រះវិហារបរិសុទ្ធចំនួនបីដែលបានស្ថាបនាឡើងនាពេលឥឡូវនេះនៅក្នុង អាក្រា ហ្គាណា , អាបៃ , នីហ្សេរីយ៉ា និង យ៉ូហាណែស្បើក អាហ្វ្រិកខាងត្បូង កំពុងតែជួយដាក់សេចក្ដីសង្ឃឹម ដ៏ថ្លៃថ្លានៅក្នុងភាពបរិសុទ្ធនៃអាពាហ៍ពិពាហ៍ ។

ខ្ញុំសូមថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទ ដែលតាមរយៈទ្រង់ទើបយើងមានដំណឹងល្អ និងការសន្យានៃការលើកដំកើង ។ ខ្ញុំថ្លែងទីបន្ទាល់អំពីព្យាការីនៅរស់របស់យើង លោក ថូម៉ាស អេស ម៉នសុន ដែលតាមរយៈលោក យើងមាន ការធានាពីការដឹកនាំរបស់ព្រះអង្គសង្គ្រោះសំរាប់ការបន្តផ្តល់សេចក្ដីសង្គ្រោះទៅដល់មនុស្សគ្រប់រូប ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល ម៉ូសេ 6:52, 57, 59 ។
2. សូមមើល ម៉ូសេ 7:19--21 ។
3. សូមមើល លោកុប្បត្តិ 6:17--22 សូមមើលផងដែរ ម៉ូសេ 7:8 ។
4. គ. និង ស. 84:14--15 ។
5. សូមមើល លោកុប្បត្តិ 8:11--21, 9:8--10 ។
6. សូមមើល លោកុប្បត្តិ 11:1--8 ។
7. សូមមើល អេធើរ 2:8--12 សូមមើលផងដែរ អេធើរ 1:33--43, 4--6 ។
8. សូមមើល លោកុប្បត្តិ 12--17, 22 សូមមើលផងដែរ អ័ប្រាហាំ 1--2 ។
9. លោកុប្បត្តិ 22:18 ។
10. សូមមើល ហេព្រើរ 7:11--12, 19--22 គ. និង ស. 84:24--25 ។
11. សូមមើល ម៉ាថាយ 28:18--20 ។
12. សូមមើល ម៉ាថាយ 20:1--16 ។
13. សូមមើល កិច្ចការ 10 ។
14. សូមមើល Bible Dictionary "ពេត្រុស" 749 ។
15. សូមមើល គ. និង ស. 58:1--12 ។
16. សូមមើលយ៉ាកុប 5:57--68 ។